# កិច្ចព្រមព្រៀងអធិស្ឋាន សម្រាប់កុមារ

**ព្រះគុណ** ឱ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ អរព្រះគុណសម្រាប់ក្ដីស្រឡាញ់ដល់ទូលបង្គំ និងនាំទូលបង្គំក្លាយជាកូនម្នាក់របស់ទ្រង់

**សេចក្ដីស្រឡាញ់** សូមជួយទូលបង្គំអោយស្រឡាញ់ និងស្ដាប់បង្គាប់ទ្រង់

**សេចក្ដីមេត្តាករុណា** សូមជួយទូលបង្គំអោយស្រឡាញ់អ្នកដទៃ ដូចដែលទ្រង់ស្រឡាញ់ទូលបង្គំដែរ

**ការផ្លាស់ប្រែ** ទូលបង្គំសោកស្ដាយសម្រាប់បាបទូលបង្គំ។ សូមលាងសំអាតទូលបង្គំ។

**ការថ្វាយបង្គំ** ទូលបង្គំនឹងសរសើរទ្រង់អស់ពីចិត្តទូលបង្គំ!

**ការប្ដេជ្ញាចិត្ត** ព្រះយេស៊ូវអើយ ទូលបង្គំចង់តាមទ្រង់ដូចជាព្រះអម្ចាស់ទូលបង្គំ។ សូមកែប្រែទូលបង្គំតាមផ្លូវដែលទ្រង់សព្វព្រះទ័យ។

**ការពឹងផ្អែក** សូមបំពេញទូលបង្គំដោយព្រះវិញ្ញាណបរិសុទ្ធទ្រង់។ ទូលបង្គំចង់ស្គាល់ផែនការទ្រង់សម្រាប់ទូលបង្គំ។

**ឥទ្ធិពល** សូមធ្វើអោយទូលបង្គំក្លាយជាអ្នកនាំសារនៃព្រះគុណ សេចក្ដីពិត និងសេចក្ដីយុត្តិធម៌របស់ទ្រង់។

**ភាពជាសិស្ស** សូមប្រើទូលបង្គំសម្រាប់សិរីល្អទ្រង់ និងនាំអ្នកដទៃ

**សិទ្ធិអំណាច** អធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

**ដើរតាមព្រះគ្រីស្ទជាមួយគ្នា**

theprayercovenant.org/children

# ខព្រះគម្ពីរចងចាំ

**ប្រស្នាអំពីចៀមដែលបាត់ · លូកា ១៥.១-៧** | មើល សេចក្តីស្រឡាញ់យ៉ាងណាហ្ន៎ ដែលព្រះវរបិតាបានផ្តល់មកយើងរាល់គ្នា ឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ ។ ១យ៉ូហាន ៣.១

**រឿងលោកអាប្រាហាំ · លោកុប្បត្តិ ១២.១-៥** | ៣៧ នោះព្រះយេស៊ូវឆ្លើយថា «ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង» ៣៨ នេះជាបញ្ញត្តយ៉ាងសំខាន់ទី១ ។ ម៉ាថាយ ២២.៣៧, ៣៨

**ពេត្រុសមិនគ្រប់លក្ខណ៍ · លូកា ២២.៥៤-៦២** | នេះជាសេចក្តីបញ្ញត្តរបស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។ យ៉ូហាន ១៥.១២

**ប្រស្នាអំពីបាវព្រាវដែលបានអត់ទោសអោយ · ម៉ាថាយ ១៨.២១-៣៥** | សូមលាងទូលបង្គំឲ្យយ៉ាងស្អាត ពីអំពើទុច្ចរិតរបស់ទូលបង្គំផង សូមលាងសំអាតអំពើបាបរបស់ទូលបង្គំ ។ ទំនុកដំកើង ៥១.២

**រឿងកំណើតព្រះយេស៊ូវ · លូកា ២.១-២០** | ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត ទូលបង្គំនឹងនិទាន ពីអស់ទាំងការអស្ចារ្យរបស់ទ្រង់។ ទំនុកដំកើង ៩.១

**ពេត្រុសមិនគ្រប់លក្ខណ៍ · លូកា ២២.៥៤-៦២** | រួចទ្រង់មានព្រះបន្ទូលទៅមនុស្សទាំងអស់ថា បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ។ លូកា ៩.២៣

**អ្នកកំសាន្តចិត្ត · យ៉ូហាន ១៤.១៥-៣១** | ចូរឲ្យបានពេញជាព្រះវិញ្ញាណវិញ។ អេភេសូ ៥.១៨ខ

**ព្រះយេស៊ូវ និងក្មេងតូចៗ · ម៉ាថាយ ១៨.១-៦** | យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត។ យ៉ូហាន ១.១៤

**សុលមកពីតើស៊ីសត្រូវបានប្តូរឈ្មោះជាប៉ុល · កិច្ចការ ៩.១-២២** | ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ។ ម៉ាថាយ ២៨.១៩

**មនុស្សខ្វាក់ម្នាក់ឈ្មោះបារទីមេ ម៉ាកុស ១០.៤៦-៥២** | ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាងខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរលើសជាងអស់ទាំងនាមផង។ ភីលីព ២.៩

The PRAYER COVENANT For Children! | 4/14 movement | FIND US ON YouVersion

©2019 The Prayer Covenant Inc. All rights reserved